# វិហារបុរាណវត្តកំពង់ត្រឡាចលើ

វត្តកំពង់ត្រឡាចលើ ជាបូជនីយដ្ឋានពុទ្ធសាសនាដ៏ល្បី ស្ថិតក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ វត្តនេះមានឈ្មោះមួយទៀតគឺ "វត្តពោធិរុក្ខារាម" ដែលគេស្គាល់ជាទូទៅថាមានវិហារចាស់មួយប្រកបដោយគំនូរបុរាណយ៉ាងវិចិត្រ។ ឯកសារនិងការនិទានខ្លះថា វត្តកំពង់ត្រឡាចលើ កកើតឡើងតាំងពីឆ្នាំ១៦៧២ វិហារកសាងឆ្នាំ១៨៤៧ និងគូរគំនូរឆ្នាំ១៨៥០។[១] ប៉ុន្តែបើផ្អែកលើលក្ខណៈសំណង់ និងតឹកតាងខ្លះ គេសន្និដ្ឋានថាវិហារកសាងក្នុងដើមសតវត្សទី២០។[២] ជាអកុសល ក្នុងរបបកម្ពុជាប្រជាធិបតេយ្យគេបានយកវិហារនេះធ្វើជាឃ្លាំងស្តុកអំបិល និងរក្សាថ្នាំបណ្តាលឱ្យខូចខាត ព្រមទាំងលុបគំនូរដោយអន្ទើ។[៣]

វិហារវត្តកំពង់ត្រឡាចលើ ដែលយើងមើលឃើញគង់វង្សដល់សព្វថ្ងៃនេះ កសាងឡើងនៅលើទីទួលមួយ មានស្រះទឹកព័ទ្ធជុំវិញទាំងបួនជ្រុង និងមានច្រកចូលទាំងបួនទិស។ វិហារនេះសង់អំពីឥដ្ឋ និងកំបោរបាយអនៅលើខឿនពីរថ្នាក់។ ខឿនថ្នាក់ទី១ ជាថ្មបាយក្រៀមធំៗដាក់តម្រៀបជុំវិញ មានកម្ពស់ប្រហែល១ម៉ែត្រ រីឯខឿនថ្នាក់ទី២ មានកម្ពស់ប្រហែលជាង១ម៉ែត្រ។ បណ្តោយវិហារមានប្រវែងជាង១៥ ម៉ែត្រ ទទឹងប្រវែងជាង៧ម៉ែត្រ ដំបូលប្រក់ក្បឿងស្រកាលេញ កសាងឡើងក្នុងលក្ខណៈជាវិហារបុរាណ បំពាក់ជហ្វា៤ (រូបលេខ១)។

ចាប់តាំងពីក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ វិហារវត្តកំពង់ត្រឡាចលើធ្លាប់បានរៀបចំ និងជួសជុលជាហូរហែ។ ឆ្នាំ១៩៨២ គេបានរៀបចំកសាងបល្ល័ង្កព្រះដីរ៍ឡើងវិញ ដោយរៀបចំតម្កល់ព្រះបដិមានានា ជាព្រះពុទ្ធរូបពុម្ពស៊ីម៉ងត៍ដូចឃើញសព្វថ្ងៃនៅត្រង់ចន្លោះល្វែងគ្រឹះផ្នែកខាងលិច។ ឆ្នាំ២០០៣ អង្គការយូណេស្កូសហការជាមួយដៃគូជំនាញ បានសិក្សាចងក្រងឯកសារ ថតរូបគំនូរលើពិតាន និងតាមជញ្ជាំងនីមួយៗ ព្រមទាំងសម្អាតជួសជុលរចនាសម្ព័ន្ធចាំបាច់។ ចុងឆ្នាំ២០១០ ដល់ដើមឆ្នាំ២០១១ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានសិក្សាអភិរក្សរចនាសម្ព័ន្ធដំបូល និងជួសជុលគំនូរ។

---

[១] Sreyleak Soun 2019: 1

[២] *Daniel Guéret & Dominique-Pierre Guéret 2017: 177*

[៣] ប្រវត្តិវត្តកំពង់ត្រឡាចលើ រៀបចំដោយមន្ទីរធម្មការនិងសាសនា ខេត្តកំពង់ឆ្នាំង ឆ្នាំ២០១១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១ វិហារវត្តកំពង់ត្រឡាចលើ (មើលពីជ្រុងពាយ័ព្យ)

ចំពោះរចនាសម្ព័ន្ធវិហារ នៅខឿនថ្នាក់ទី២ គេឃើញមានជណ្តើរចំនួន៦ ដោយនៅផ្នែកខាងមុខមានជណ្តើរពីរ និងទ្វារពីរ ហើយនៅផ្នែកខាងក្រោយ ក៏ឃើញមានជណ្តើរពីរ និងទ្វារចេញចូលពីរដែរ។ ប៉ុន្តែនៅផ្នែកចំហៀងទាំងសងខាង គេឃើញមានជណ្តើរម្ខាងមួយដូចគ្នា ហើយពុំមានទ្វារចេញចូលឡើយ ពោលគេរៀបចំឱ្យមានបង្អួចម្ខាង៥ (រូបលេខ២)។ ចំណែកឯជើងជញ្ជាំងខាងក្រៅត្រង់ចន្លោះរបៀងបាំងសាច រចនាជាល្បាក់ធំៗកម្ពស់ត្រឹមលើចង្កេះ (រូបលេខ៣)។



រូបលេខ២ វិហារមើលពីចំហៀង (ខាងត្បូង)



រូបលេខ៣ ល្បាក់របៀងបាំងសាច

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ក្បាច់ស៊ុមទ្វារ គេប្រើជាក្បាច់ភ្ញីទេស ដែលនៅផ្នែកណ្តាលមានរូបរាហ៊ូនិងនៅផ្នែកចំហៀងទ្រចុងទងក្បាច់ គេរចនាឱ្យមានលំនាំដូចគ្រុឌទ្រចុងដំបូល (រូបលេខ៤)។ រីឯក្បាច់ស៊ុមបង្អួចជុំវិញទាំងអស់ គេរចនាមានលក្ខណៈស្រដៀងនឹងមកុដ។ ប៉ុន្តែជាការគួរឱ្យសម្គាល់ នៅលើសន្ទឹកទ្វារ និងបង្អួចនីមួយៗ គឺជាផ្ទៃឈើលាតទាំងអស់ ពុំមានក្បាច់ក្បូរលម្អអ្វីបន្តិចសោះ។ ដូច្នេះសន្ទឹកទ្វារបង្អួចទាំងនេះ ប្រហែលគេប្តូរផ្លាស់ក្នុងពេលណាមួយនៃសម័យក្រោយៗមក។



រូបលេខ៤ ក្បាច់ស៊ុមទ្វារ



រូបលេខ៥ ក្បាច់ស៊ុមបង្អួច

ដោយឡែកហោជាងទាំងសងខាងនៃវិហារនេះ គេរចនាជាភ្ញីទេសយ៉ាងរស់រវើកលាបពណ៌ដីលែង រំលេចជុំវិញរង្វង់ពងក្រពើដែលចារឹកកាលបរិច្ឆេទ និងឈ្មោះអ្នកមានសទ្ធាសាងបូជាព្រះរតនត្រ័យ។ ហោជាងទាំងពីរចារឹកកាលបរិច្ឆេទ "ពុទ្ធសករាជ២៤៦៨" ដែលត្រូវនឹងរវាងគ្រិស្តសករាជ១៩២៥(រូបលេខ៦-៧)។[៤] ប៉ុន្តែយ៉ាងណាក៏ដោយតាមរយៈរូបថតសាលាបារាំងចុងបូព៌ាប្រទេស *(EFEO)* ថតឆ្នាំ១៩២៩ *(EFEO_CAM15561)* បង្ហាញថាហោជាងវិហារវត្តកំពង់ត្រឡាចលើក្នុងគ្រានោះ រចនាលម្អដោយក្បាច់ភ្ញីទេស រំលេចជុំវិញរូបមួយមានលំនាំដូចប្រាសាទ(?) (រូបលេខ៨)។ ហោជាងដើមនោះទំនងធ្លាក់អំពីឈើ ពោលគឺពុំមែនជាហោជាងរចនាលម្អអំពីស៊ីម៉ងត៍ដូចសព្វថ្ងៃឡើយ។ ដូច្នេះហោជាងដែលឃើញសព្វថ្ងៃ ព្រមទាំងចារឹកកាលបរិច្ឆេទនោះ ទំនងជួសជុលប្តូរផ្លាស់ពេលក្រោយហើយចារឹកកត់ទុកកាលបរិច្ឆេខាងលើទុកជាចំណាំតមក។

[៤] បើយោងតាមកាលបរិច្ឆេទនេះ ព្រះវិហារកសាងក្រោយសាលាធម្មសភាចាស់៣ឆ្នាំ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



*រូបលេខ៦ ហោជាងខាងកើត*



*រូបលេខ៧ ហោជាងខាងលិច*



*រូបលេខ៨ ហោជាង ឆ្នាំ១៩២៩ **(©EFEO)***

*បើប្រៀបធៀបរូបថតឆ្នាំ១៩២៩ ខាងលើនោះគេឃើញថា ការលម្អក្បាលសសររបៀងបាំងសាចជុំវិញវិហារ ក្បាច់លម្អរង់ស្បូវ និងនាគដងក្តារទាំងអស់ក៏បានប្តូរផ្លាស់ដូចហោជាងទាំងពីរដែរ។ ទន្ទឹមនឹងនេះ ប្រសិនបើគេពិនិត្យមើលរូបថតសាលាបារាំងចុងបូព៌ាប្រទេសថតក្នុងឆ្នាំ១៩២៩ មួយសន្ទឹកផ្សេងទៀត (EFEO_CAM15591) (រូបលេខ៩) គេឃើញថាព្រះជីវ៍ដើមនៃវិហារនេះតម្កល់លើបល័ង្កខ្ពស់ក្នុងបុស្បុក ដែលមានព្រះបដិមាក្នុងកាយវិការផ្ចាញ់មារតូចមួយតម្កល់នៅខាងមុខ។ ប៉ុន្តែព្រះជីវ៍បច្ចុប្បន្ន ជាព្រះបដិមាចាក់ពុម្ពស៊ីម៉ងត៍(?) ក្នុងកាយវិការផ្ចាញ់មារ តម្កល់លើបល័ង្កសាងក្នុងឆ្នាំ១៩៨២ (រូបលេខ១០)។ រីឯព្រះបដិមាផ្ចាញ់មារដែលធ្លាប់តម្កល់មុខព្រះជីវ៍ចាស់ គេបានរំកិលតម្កល់ទុកក្រោយព្រះជីវ៍ធំសព្វថ្ងៃ (រូបលេខ១១)។ លើសពីនេះ គេបានកែសម្រួលសសរខាងក្នុងទាំងអស់ ដោយលុបឆ្នូតចង្អូរបណ្តោយសសរ និងប្តូរការ៉ូបាតផងដែរ។*



*រូបលេខ៩ ព្រះជីវ៍ចាស់ **(©EFEO)***



*រូបលេខ១០ ព្រះជីវ៍បច្ចុប្បន្ន*



*រូបលេខ១១ ព្រះបដិមាផ្ចាញ់មារចាស់*

*អត្ថបទដោយៈ ហៀន សុវណ្ណមរកត*

ចំណែកឯគំនូរក្នុងវិហារខាងលើនេះ ជាប្រភេទគំនូរបុរាណដ៏ល្អវិចិត្រ និយាយអំពីអន្ទើ ឬតួអង្គខ្លះក្នុងរឿងរាមកេរ្តិ៍ រឿងពុទ្ធប្រវត្តិ និងរឿងជាតក។ រឿងរាមកេរ្តិ៍ គេគូរនៅលើពិតាន ត្រង់លើចន្លោះល្វែងគ្រឹះ តួអង្គមួយភាគធំទៀតគូរនៅត្រង់ហប់ខ្យល់ និងតាមគែមបង្អួច(រូបលេខ១២-១៣)។ រឿងពុទ្ធប្រវត្តិ និងរឿងជាតក គេគូរលើជញ្ជាំងជុំវិញ តែរឿងពុទ្ធប្រវត្តិគេគូរនៅបន្ទាត់ខាងលើ (រូបលេខ១៤-១៥) រីឯរឿងជាតកនៅបន្ទាត់ខាងក្រោម (រូបលេខ១៦-១៧)។ អ្វីដែលគួរឱ្យកត់សម្គាល់នៃគំនូរបុរាណក្នុងវិហារនេះ នៅត្រង់អន្ទើខ្លះក្នុងរឿងពុទ្ធប្រវត្តិ និងរឿងជាតក គេបានគូរបញ្ចូលបន្ថែមទិដ្ឋភាពជីវភាពរស់នៅរបស់អ្នកស្រុក និងល្បែងរបាំផ្សេងៗ (រូបលេខ១៨-១៩)។



រូបលេខ១២ អន្ទើខ្លះក្នុងរឿងរាមកេរ្តិ៍គូរលើពិតាន



រូបលេខ១៣ តួអង្គខ្លះក្នុងរឿងរាមកេរ្តិ៍គូរលើគែមបង្អួច

KHMER CIVILIZATION



រូបលេខ១៤-១៥ អន្ទើនានាក្នុងរឿងពុទ្ធប្រវត្តិ គូរលើជញ្ជាំងជុំវិញត្រង់បន្ទាត់ខាងលើ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




រូបលេខ១៦-១៧ អន្ទើខ្លះក្នុងរឿងជាតក ដែលគូរនៅបន្ទាត់ខាងក្រោម




រូបលេខ១៨-១៩ ទិដ្ឋភាពជីវភាពអ្នកស្រុក និងការសម្ដែងល្បែងរបាំផ្សេងៗ

រួមសេចក្ដីមក វិហារវត្តកំពង់ត្រឡាចលើ ជាស្ថាបត្យកម្មពុទ្ធសាសនាដ៏ល្អវិសេស ដ្បិតមានគំនូរបុរាណល្អឯកប្រកបដោយខ្លឹមសារយ៉ាងសំខាន់ៗ ប៉ុន្តែការលើកឡើងថាវត្តនេះកកើតក្នុងចុងសតវត្សទី១៧ ហើយសង់វិហារនិងគូរគំនូររវាងពាក់កណ្ដាលសតវត្សទី១៩ ហាក់ជាព័ត៌មានគួរឱ្យពិចារណា ព្រោះចន្លោះពេលកកើតវត្ត និងកសាងវិហារឃ្លាតគ្នារហូតដាង២០០ឆ្នាំ។ លើសពីនេះក្នុងកំណត់ហេតុលោក ហ្សង់ មូរ៉ា (Jean Moura) អំពី "ដំណើរពីភ្នំពេញទៅកាន់ខេត្តពោធិសាត់ ឆ្នាំ១៨៨៣"[៥] និយាយពីភូមិកំពង់ត្រឡាច តែពុំមានចំណុចណានិយាយពីវត្តឈ្មោះកំពង់ត្រឡាចឡើយ។ ម្យ៉ាងទៀត សាលាធម្មសភាវត្តនេះកសាងក្នុងឆ្នាំ១៩២២។ ដូច្នេះវិហារទំនងកសាងឡើងក្នុងរវាងដើមសតវត្សទី២០ ពោលគឺកសាងក្រោយសាលាធម្មសភាដូចបណ្ដាវត្តទូទៅដែរ៕

[៥] សូមអាន៖ ហ្សង់ មូរ៉ា, ១៨៨៣ (ប្រែសម្រួលនិងរៀបរៀងដោយ បណ្ឌិតសភាចារ្យ គឿង សកុណា, ២០២២) "ពីភ្នំពេញទៅកាន់ខេត្តពោធិសាត់ អមដំណើរព្រះមហាក្សត្រកម្ពុជា និងរាជបរិពារ"

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ហ្សង់ មូរ៉ា

១៨៨៣, *ពីភ្នំពេញទៅកាន់ខេត្តពោធិសាត់ អមដំណើរព្រះមហាក្សត្រកម្ពុជា និងរាជបរិពារ* [ប្រែសម្រួលនិងរៀបរៀងដោយ បណ្ឌិតសភាចារ្យ គឿង សកុណា, ២០២២], មូព្រៃ, ភ្នំពេញ

Daniel Guéret & Doninique-Pierre Guéret

2017, *The Khmer Pagoda,* Kam editions

Sreyleak SOUN

2019, *Studies on The Deterioration, Conservation and Pigment Composition of Mural Paintings in Vihear Kompong Tralach Leu, Kompong Chhnang Province, Cambodia,* Silpakorn University, Bangkok

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត